ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

សំណុំរឿងព្រហ្មទណ្ឌលេខ:១៥៨
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខ:០៧ “ខ”
ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ និងប្រកាសសាលក្រមនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ នៅសាលាដំបូងខេត្តព្រះវិហារ ដែលមានសមាសភាពដូចតទៅ៖

<u>ចៅក្រមជំនុំជម្រះ</u>

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងអយ្យការ</u>

-លោក [redacted] ជាតំណាងអយ្យការ

<u>ក្រឡាបញ្ជីសវនាការ</u>

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងលេខ:១៥៨ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១/.ឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកប្រា សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងមានទីលំនៅមុនពេលឃុំខ្លួនស្ថិតនៅ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] “ស” ម្តាយឈ្មោះ [redacted] “រ” ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៣ នាក់ មានមុខរបរជា ជាងសិប្បកម្ម ទោសពីមុនគ្មាន ជានីតិជន។



Scanned with CamScanner

២/.ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតស្ថិតនៅភូមិថ្មគោល ឃុំថ្មគោល ស្រុកថ្មគោល ខេត្តបាត់ដំបង និងមានទីលំនៅមុនពេលចាប់ឃាត់ខ្លួន[redacted] ខេត្ត ព្រះវិហារ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ[redacted]មានកូនចំនួន០១ នាក់ មានមុខរបរជា ជាងសិប្បកម្ម ទោសពីមុនគ្មាន ជានីតិជន។

៣/.ឈ្មោះ [redacted] ម៉េង ហៅ ជា ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតស្ថិតនៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ និងមានទីលំនៅបច្ចុ[redacted]ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន។

៤/.ឈ្មោះ[redacted]មួយអេង ហៅ ញ៉ាំញ់, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជ្រូវបាសាក់ ឃុំព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងមានទីលំនៅមុនពេលចាប់ឃាត់ខ្លួនស្ថិ[redacted] ខេត្ត ព្រះវិហារ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ [redacted] មានកូន០៤ នាក់ ទោសពីមុនគ្មាន ជានីតិជន។

ត្រូវបានចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

វត្ថុចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លាមានចំនួន០១ កញ្ចប់ធំ និង០៥ កញ្ចប់តូច មានទម្ងន់១០៧,៣១ ក្រាម, ប្រាក់រៀលចំនួន ១៤.000.000 (ដប់បួនលាន)រៀល, ប្រាក់ដុល្លារចំនួន ៤៧៤ (បួនរយចិតសិបបួន) ដុល្លារ, រថយន្តម៉ាកកាមេរីពណ៌សំបកឪឡឹកស៊េរីឆ្នាំ១៩៩៥ ពាក់ស្លាកលេខ ភ្នំពេញ2A-7624 ចំនួន០១ គ្រឿង (មានសោ), កាំភ្លើងខ្លីលេខ S1366 ចំនួន០១ ដើម (ខូច) និងគ្រាប់ចំនួន០១ គ្រាប់, ទូរស័ព្ទម៉ាកណូគាពណ៌ខ្មៅ (ចុចពិល) ចំនួន០២ គ្រឿង, អត្តសញ្ញាណប័ណ្ណឈ្មោះ ហូ សំអាត ចំនួន០១, កាត Angkor Tep Group ចំនួន០១, កាំភ្លើងកែច្នៃចំនួន០១ ដើម, កាំបិតវែងចំនួន០២ ដើម, សៀវភៅចុះបញ្ជីលក់ថ្នាំញៀនចំនួន០១ ក្បាល, កាបូបខ្មៅពណ៌ខ្មៅចំនួន០១, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១ (គ្មានថ្ម), ថង់សំរាប់ច្រកថ្នាំញៀនចំនួន០១ កញ្ចប់ធំ, ស្ករក្រាមចំនួន០១ ប្រអប់, សាជូរចំនួន០១ កញ្ចប់ធំ, ប្រអប់ដាក់ថ្នាំញៀនចំនួន០១ ប្រអប់, កំប៉ុងដាក់ថ្នាំញៀនចំនួន០១, ឧបករណ៍ធ្វើតេស្តទឹកនោមចំនួន០២, វិក័យប័ត្រវីងចំនួន១០ សន្លឹក និងសម្ភារៈប្រើប្រាស់ថ្នាំញៀនចំនួន០១ កញ្ចប់ធំ។

## អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង១១ និង៤០ នាទី កម្លាំងអធិការដ្ឋាននគរបាលស្រុកជាំក្សាន្ត បានចុះធ្វើការបង្ក្រាប និងឆែកឆេរករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀនស្ថិតនៅភូមិជាំក្សាន្ត ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បង្កឡើងដោយជនសង្ស័យខាងលើ ត្រូវសមត្ថកិច្ចដកហូតបាននូវវត្ថុតាងរួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីនម្សៅពណ៌ស (ម៉ាទឹកកក) ចំនួន០១ កញ្ចប់ធំ និង០៥ កញ្ចប់តូច មានទម្ងន់ ១០៧,៣១ ក្រាម ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១ រថយន្តកាមេរីពណ៌សំបកឪឡឹកចំនួន០១ គ្រឿង ពាក់ស្លាកលេខភ្នំពេញ2A-7624 ទូរស័ព្ទដៃចំនួន



Scanned with CamScanner

០២ គ្រឿង លុយដុល្លារចំនួន៤៧៤ ដុល្លារអាមេរិក លុយខ្មែរចំនួន ១៤,០០០,០០០៛ កាំភ្លើងខ្លីចំនួន០១ ដើម និងគ្រាប់កាំភ្លើងចំនួន០១ គ្រាប់ កាំបិតចំនួន០២ និងពូថៅចំនួន០១ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួនទៀត មកជាមួយពិតប្រាកដមែន។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ:២១៥ ដ.ស.ព/១៧ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ដែលសុំប្តឹងទៅក្រុមស៊ើបសួរបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted] សំណាង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ម៉េង ហៅ [redacted]ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] មួយអេង ហៅ ញ៉ាំញ៉ូ, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

បានឃើញ ដីកាដំណោះស្រាយលេខ:៨៩/២០១៨ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ[redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted] ម៉េង ហៅ [redacted]ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted]មួយអេង ហៅ ញ៉ាំញ៉ូ, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សំអាត បានឆ្លើយថា៖ ខ្លួនមិនទទួលយកការចោទប្រកាន់នោះទេ ពីព្រោះពេលដែលគេឆែកឆេរផ្ទះរបស់ខ្លួនមិនឃើញថ្នាំញៀននោះទេ ប៉ុន្តែគេបានរកឃើញនៅតាមរបងផ្ទះរបស់ខ្លួន និងនៅរោងឈើរបស់ខ្លួន។ ខ្លួនក៏ធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ផាន់នី បានម្តង ដោយគាត់ជាជាងឈើនៅកន្លែងសិប្បកម្មរបស់ខ្លួនបានមួយរយៈ ហើយគាត់បានចេញពីផ្ទះរបស់ខ្លួនបានបីទៅបួនថ្ងៃក៏ត្រូវសមត្ថកិច្ចមកចាប់ខ្លួនតែម្តង។ ឈ្មោះ ផាន់នី បានឈ្លោះគ្នាជាមួយខ្លួនទើបគាត់ចេញពីផ្ទះរបស់ខ្លួន។ បានជាខ្ញុំប្រើប្រាស់គ្រឿងជាមួយឈ្មោះ ផាន់នី ដោយសារថ្ងៃនោះខ្លួនស្រវឹងស្រាផង ហើយប្រើប្រាស់តែម្តង។ ខ្លួនមិនដែលបានអោយឈ្មោះ ផាន់នី ទៅទិញថ្នាំញៀនអ្វីនោះទេ។ ខ្លួនស្គាល់ឈ្មោះ[redacted] សំណាង ដោយសារតែគាត់ជាជាងឈើ។ នៅថ្ងៃកើតហេតុប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] មួយអេង បានទៅទិញស្រូវនៅឯខេត្តបាត់ដំបង។

-ជនជាប់ចោទឈ្មោះ[redacted] សំណាង បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ថាគ្រឿងញៀនទាំងអស់ជារបស់ខ្លួន ដោយខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ ផាន់នី ក្នុងម្នាក់៥០០ ដុល្លារ ហើយឈ្មោះ ផាន់នី ជាអ្នកទៅទិញពីឈ្មោះ ខេម នៅស្រែអែម។ បានជាខ្លួនទិញមកច្រើនដោយសារតែអ្នកលក់ថា បើទិញតិចគេមិនលក់នោះទេ ចឹងហើយបានជាខ្លួនទិញមកច្រើនបែបនេះ។ ខ្លួនទិញយកមកគ្រាន់តែប្រើប្រាស់តែប៉ុណ្ណោះ ពីព្រោះខ្លួនធ្វើការធ្ងន់ៗ ដូចជាធ្វើគ្រែយក្សជាដើម។

-ជនជាប់ចោទឈ្មោះ [redacted] មួយអេង បានឆ្លើយថា៖ ខ្លួនបានលែងលះជាមួយឈ្មោះ [redacted] សំអាត តាំងពី១០ឆ្នាំមុនមកម្លេះ។ ផ្ទះរបស់ឈ្មោះ [redacted] សំអាត ខ្លួនបានមកទេ តាំងពីបែកគ្នា។ ករណីអ្នកទាំងពីរនាក់នេះ ខ្លួនមិនបានដឹងអ្វីនោះទេ។ ខ្លួនមិនបានស្គាល់ឈ្មោះ[redacted]ណារិទ្ធ ទេ ខ្លួនសូមបដិសេធនៅក្នុងសំណុំរឿងក្តីនេះ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ម៉េង ហៅ [redacted] ផាន់នី អវត្តមាននាពេលសវនាការ។

-តុលាការបានអោយក្រឡាបញ្ជីអានកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] ចលនា បានឆ្លើយថា៖ តាមចម្លើយរបស់ឈ្មោះ [redacted] ណារិទ្ធ ភេទប្រុស កំពុងជាប់ពន្ធនាគារខេត្តព្រះវិហារ ថាគាត់បានទិញថ្នាំញៀនពីឈ្មោះ [redacted] មួយអេង ហៅ ញាញ់ ហៅ ចិន ភេទស្រី អាយុ៣០ឆ្នាំ ជាប្រពន្ធរបស់ឈ្មោះ [redacted] សំអាត ដោយគេយកមកអោយតាមផ្ទះ តម្លៃ ១០ ម៉ឺនរៀល ជាច្រើនដង ហើយក៏មិនបានដឹងថាឈ្មោះ [redacted] មួយអេង បានថ្នាំញៀនមកពីណាទេ។ ឈ្មោះ [redacted] ណារិទ្ធ ទាក់ទងទិញថ្នាំញៀនតាមរយៈលេខទូរស័ព្ទ [redacted] ជាលេខទូរស័ព្ទរបស់ឈ្មោះ [redacted] មួយអេង។

ខាងកម្លាំងរបស់ខ្លួនបានអោយឈ្មោះ [redacted] ណារិទ្ធ ទាក់ទងទៅឈ្មោះ [redacted] មួយអេង គាត់ថាអត់ស្គាល់ទេ ពីព្រោះគាត់ជាអ្នកភ្នំពេញ មិនមែនជាអ្នកភូមិធម្មជាតិទេ និងបានអោយឈ្មោះនេះឈប់ទាក់ទង ក៏បានអោយខាងកម្លាំងនគរបាលប៉ុស្តិ៍ស្រអែម តាមដានវិញម្តង។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ គេផ្តល់ពត៏មានអោយកម្លាំងថា ផ្ទះឈ្មោះ [redacted] មួយអេង មានថ្នាំញៀននៅក្នុងផ្ទះ ព្រោះឃើញមានមនុស្សចេញចូលច្រើន។ នៅថ្ងៃដដែលនោះ វេលាម៉ោង១១ និង៤០ នាទីថ្ងៃត្រង់ កម្លាំងរបស់ខ្លួនបានសុំយោបល់ពីលោកព្រះរាជអាជ្ញារង [redacted] ប៉េងស្រ៊ុន ដើម្បីឆែកឆេរផ្ទះឈ្មោះ [redacted] មួយអេង គាត់អោយយើងចូលឆែកឆេរ បើម្ចាស់ផ្ទះគេអោយចូលឆែកឆេរ យើងបានសុំម្ចាស់ផ្ទះឈ្មោះ [redacted] សំអាត ចូលឆែកឆេរ មួយសន្ទុះទើបឈ្មោះ [redacted] សំអាត អោយយើងចូលឆែកឆេរ។ ពេលចូលទៅដំបូង មានអធិការរងស្រុកជាំក្សាន្ត និងតំណាងមេភូមិ តំណាងមេឃុំស្រអែម សរុបទាំងអស់ចំនួន៣៤ នាក់ ចាប់ផ្តើមឆែកឆេរពីក្រោមផ្ទះ ឡើងទៅលើ នៅក្រោមផ្ទះឃើញថ្នាំញៀនមួយកញ្ចប់ធំ នៅក្រោមឈើ ក្រោមផ្ទះ និងមួយកញ្ចប់តូចក្រោមផ្ទះ ខាងកើត កន្លែងលាក់កញ្ចប់ធំ ក្រោមឈើដូចគ្នា ហើយឃើញឈ្មោះ [redacted] សំណាង កាន់កំប៉ុងមួយ រត់ទៅខាងក្រោយផ្ទះយកទៅបោះចោលក្រោយផ្ទះផ្លូវទៅរោងសិប្បកម្ម ដីឡូដីធំ យើងរើសបានកំប៉ុង ឃើញមានថ្នាំញៀនបួនកញ្ចប់តូច និងប្រដាប់ប្រដាប្រើប្រាស់ថ្នាំញៀន រួចឈ្មោះ [redacted] សំណាង រត់ចូលមកក្រោមផ្ទះវិញ ពេលឃើញកម្លាំងយើងមកពីក្រោយផ្ទះ។ កម្លាំងយើងឆែកឆេរក្រោមផ្ទះរួចហើយឡើងទៅលើផ្ទះឃើញមានលុយមានចំនួន ១៥៨១៩០០០ (ដប់ប្រាំលានប៉ែតសិបមួយម៉ឺនប្រាំបួនពាន់) រៀល លុយដុល្លារចំនួន ៤៧៤ (បួនរយចិត្តសិបបួន) ដុល្លារអាមេរិក។ រួចបានទៅឆែកឆេរនៅរោងសិប្បកម្ម ឃើញមានកាំភ្លើងខ្លីមួយដើម លាក់ក្រោមឈើដាក់ក្នុងចានមានគ្រាប់ចំនួនមួយគ្រាប់មិនស្គាល់ម៉ាក និងកាំភ្លើងខ្យល់ថ្មៃ ខូចចំនួន០១ ដើម ទុកនៅកៀនរបងរោងសិប្បកម្ម។ កម្លាំងយើងប្រមូលភស្តុតាង និងឃាត់ខ្លួនឈ្មោះ [redacted] សំអាត ភេទប្រុស និងឈ្មោះ [redacted] សំណាង ភេទប្រុស កសាងសំណុំរឿងបញ្ជូនមកតុលាការ។ ពេលកម្លាំងយើងចុះទៅឆែកឆេរផ្ទះពុំឃើញឈ្មោះ [redacted] មួយអេង នៅផ្ទះឡើយ តែឃើញគេទូរស័ព្ទមកឈ្មោះ [redacted] សំអាត និងគេទូរស័ព្ទទៅប្រពន្ធរបស់ឈ្មោះ [redacted] សំណាង តែកម្លាំងពុំអោយនិយាយទូរស័ព្ទឡើយ ព្រោះកម្លាំងយើងកំពុងឆែកឆេរ។ តាមការសន្និដ្ឋាន និងស្រាវជ្រាវថ្នាំញៀននៅក្នុងផ្ទះនោះ ជារបស់ឈ្មោះ [redacted] មួយអេង និងឈ្មោះ [redacted] សំអាត និងជាមុខសញ្ញាជួញដូរថ្នាំញៀនដ៏សកម្មទៀតផង។

-ការធ្វើសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ: ឆ្លងតាមការពិភាក្សាដេញដោលរួចមក ឃើញថាជនជាប់ចោទឈ្មោះ [redacted] សំណាង បានសារភាពថា គ្រឿងញៀនទាំងអស់ជារបស់ខ្លួន និងឈ្មោះ [redacted] ផាន់នី ។ ចំណែកឈ្មោះ [redacted] សំអាត និងឈ្មោះ [redacted] មួយអេង បានឆ្លើយបដិសេធថា ខ្លួនមិនពាក់ព័ន្ធរឿងគ្រឿងញៀននេះទេ ប៉ុន្តែចម្លើយនេះមិនអាចធ្វើ



Scanned with CamScanner

អោយតំណាងអយ្យការជឿបានទេ   ហេតុដូចនេះតំណាងអយ្យការសូមធ្វើការរក្សាបទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ។

-ការធ្វើសេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] វ៉ាន់នី ការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] សំអាត៖ ក្រោយពីបានពិភាក្សាសួរដេញដោលរួចមកឃើញថា កូនក្តីរបស់ខ្លួនមិនបានពាក់ព័ន្ធនឹងរឿងគ្រឿងញៀននេះ គ្រឿងញៀនទាំងអស់ជារបស់ឈ្មោះ [redacted] សំណាង ហេតុនេះ គប្បីតុលាការពិចារណាលើកលែងចោទប្រកាន់កូនក្តីរបស់ខ្លួនផង។

-ការធ្វើសេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] កែវស៊ីវិន ការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] សំណាង, [redacted] ម៉េង ហៅ [redacted] ផាន់នី និងឈ្មោះ [redacted] មួយអេង ហៅ ញ៉ាញ់, ចិន៖ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សំណាង បានសារភាពអស់ហើយ ហើយកូនក្តីរបស់ខ្លួនឈ្មោះ [redacted] មួយអេង ហៅ ញ៉ាញ់, ចិន បានបដិសេធទាំងស្រុង ហេតុនេះ គប្បីតុលាការពិចារណាលើកលែងចោទប្រកាន់ និងបន្ធូរបន្ថយទោសកូនក្តីខ្លួនផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង ៖ សូមឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] មួយអេង, [redacted] សំអាត ៖ សូមអោយតុលាការលើកលែងចោទប្រកាន់ខ្លួនផង ពីព្រោះខ្លួនមិនពាក់ព័ន្ធក្នុងរឿងក្តីនេះទេ។

-ក្រោយពីបានពិភាក្សាសួរដេញដោលនាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ
## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ម៉េង ហៅ [redacted] ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] មួយអេង ហៅ ញ៉ាញ់, [redacted] ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារបញ្ជូនទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ តាមដីកាដំណោះស្រាយលេខ:៨៩/២០១៨ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ តាមមាត្រា៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការពិចារណា។

-តាមដីកាដំណោះស្រាយលេខ:៨៩/២០១៨ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួររបស់សាលាដំបូងខេត្តព្រះវិហារ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ម៉េង ហៅ [redacted]ាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] មួយ



Scanned with CamScanner

អេង ហៅ ញ៉ាំញ់, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ មកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ តាមមាត្រា៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ប៉ុន្តែតុលាការបានធ្វើការគណនាទៅលើសារធាតុញៀន ដែលបានចាប់យកមានទម្ងន់១០៧,៣១ ក្រាម នឹងដោយផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បរិមាណធាតុសុទ្ធមានចំនួន ៧៨,១០% យើងបានបរិមាណធាតុសុទ្ធទម្ងន់៨៣, ៨០៩ ក្រាម។ ផ្អែកតាមទម្ងន់បរិមាណធាតុសុទ្ធនេះ (៨៣,៨០៩ ក្រាម) តុលាការត្រូវផ្តន្ទាទោសទៅលើជនជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌនេះតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញ។

-ជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយសារភាពថា គ្រឿងទាំងអស់ជារបស់ខ្លួន និងឈ្មោះ [redacted] ផាន់នី ដោយពួកខ្លួនបានចូលលុយគ្នាទិញក្នុងម្នាក់៥០០ដុល្លារ ដោយឈ្មោះ [redacted] ផាន់នី ជាទៅទិញពីឈ្មោះ [redacted] នៅស្រអែម។ គប្បីតុលាការពិចារណា។

-ជនជាប់ចោទឈ្មោះ [redacted] សំអាត បានឆ្លើយថា គ្រឿងញៀនទាំងអស់នោះមិនមែនជារបស់ខ្លួនទេ ខ្លួនគ្រាន់តែធ្លាប់ប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] ផាន់នី តែប៉ុណ្ណោះ អ្វីផ្សេងពីនេះខ្លួនសូមបដិសេធ។ ចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតការចោទប្រកាន់ គប្បីតុលាការពិចារណា។

-ជនជាប់ចោទឈ្មោះ [redacted] មួយអេង ហៅ ញ៉ាំញ់, ចិន បានឆ្លើយថា ខ្លួនមិនពាក់ព័ន្ធរឿងក្តីគ្រឿងញៀននេះទេ ខ្លួនសូមបដិសេធនៅក្នុងរឿងក្តីនេះ។ ចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតការចោទប្រកាន់ គប្បីតុលាការពិចារណា។

-តាមអំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] ចលនា បង្ហាញថា [redacted] មួយអេង ពិតជាឈ្មួញលក់គ្រឿងញៀនប្រាកដមែន។

-សារធាតុញៀនចាប់ប្រមូលយកបានគឺ នៅខាងក្រោមផ្ទះរបស់ឈ្មោះ [redacted] សំអាត និងឈ្មោះ [redacted] មួយអេង គប្បីតុលាការពិចារណា។

-តាមចម្លើយរបស់ជនជាប់ចោទ, តាមការពិនិត្យភស្តុតាងផ្សេងៗ នៅក្នុងសំណុំរឿង ឃើញថាមានភាពស៊ីសង្វាក់គ្នាបញ្ជាក់បានថាពិតជាមាននូវអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សំអាត, [redacted] សំណាង, [redacted] មួយអេង ហៅ ញ៉ាំញ់, ចិន និងឈ្មោះ [redacted] ម៉េង ហៅ [redacted] ផាន់នី ប្រាកដមែន។ អំពើនេះល្មើសទឹងមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សំអាត [redacted] សំណាង [redacted] មួយអេង ហៅ ញ៉ាំញ់, ចិន និងឈ្មោះ [redacted] ម៉េង ហៅ [redacted] ផាន់នី ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ តាមមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

-គ្មានភស្តុតាងណាបញ្ជាក់ថាជនជាប់ចោទជាជនវិកលចរិក ឬវិបល្លាសស្មារតីឡើយ ផ្ទុយទៅវិញ ជនជាប់ចោទជាបុគ្គលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទក៏ដោយសារតែ ភាពក្រីក្រ ភាពអវិជ្ជមាន ខ្វះការអប់រំ គប្បីតុលាការពិចារណា។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ តុលាការនិងពិចារណាសម្រេចតាមច្បាប់។

-សំដីចុងក្រោយរបស់ជនជាប់ចោទស្នើសុំអោយតុលាការបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា។

-វត្ថុដែលចាប់យករួមមានម្សៅក្រាមពណ៌សថ្លាមានចំនួន០១ កញ្ចប់ធំ និង០៥ កញ្ចប់តូច មានទម្ងន់១០៧,៣១ ក្រាម, ប្រាក់រៀលចំនួន ១៤.០០០.០០០ (ដប់បួនលាន)រៀល, ប្រាក់ដុល្លារចំនួន ៤៧៤ (បួនរយចិតសិបបួន) ដុល្លារ, រថយន្តម៉ាកកាមេរីពណ៌សំបកឪឡឹកស៊េរីឆ្នាំ១៩៩៥ ពាក់ស្លាកលេខ ភ្នំពេញ2A-7624 ចំនួន០១ គ្រឿង (មានសោ), កាំភ្លើងខ្លីលេខ S1366 ចំនួន០១ ដើម (ខូច) និងគ្រាប់ចំនួន០១ គ្រាប់, ទូរស័ព្ទម៉ាកណូគាពណ៌ខ្មៅ (ចុចពិល) ចំនួន០២ គ្រឿង, អត្តសញ្ញាណប័ណ្ណឈ្មោះ ហូ សំអាត ចំនួន០១, កាត Angkor Tep Group ចំនួន០១, កាំភ្លើងកែច្នៃចំនួន០១ ដើម, កាំបិតផែងចំនួន០២ ដើម, សៀវភៅចុះបញ្ជីលក់ថ្នាំញៀនចំនួន០១ ក្បាល, កាបូបខ្មៅពណ៌ខ្មៅចំនួន០១, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១ (គ្មានថ្ម), ថង់សំរាប់ច្រកថ្នាំញៀនចំនួន០១ កញ្ចប់ធំ, ស្ករក្រាមចំនួន០១ ប្រអប់, សាជូរចំនួន០១ កញ្ចប់ធំ, ប្រអប់ដាក់ថ្នាំញៀនចំនួន០១ ប្រអប់, កំប៉ុងដាក់ថ្នាំញៀនចំនួន០១, ឧបករណ៍ធ្វើតេស្តទឹកនោមចំនួន០២, វិក័យប័ត្រវីងចំនួន១០ សន្លឹក និងសម្ភារៈប្រើប្រាស់ថ្នាំញៀនចំនួន០១ កញ្ចប់ធំ គប្បីរឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ**

**វិនិច្ឆ័យសេចក្តី**

១./ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ម៉េង ហៅ [redacted] ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] មួយរេង ហៅ ញ៉ាំញ៉ៈ ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ចំនួន២០ (ម្ភៃ) លានរៀល ក្នុងម្នាក់ៗ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ តាមមាត្រា៤០ កថាខណ្ឌ៦ ចំណុច៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២./វត្ថុចាប់យកមានម្សៅក្រាមពណ៌សថ្លាមានចំនួន០១ កញ្ចប់ធំ និង០៥ កញ្ចប់តូច មានទម្ងន់១០៧,៣១ ក្រាម, ប្រាក់រៀលចំនួន ១៤.០០០.០០០ (ដប់បួនលាន)រៀល, ប្រាក់ដុល្លារចំនួន ៤៧៤ (បួនរយចិតសិបបួន) ដុល្លារ, រថយន្តម៉ាកកាមេរីពណ៌សំបកឪឡឹកស៊េរីឆ្នាំ១៩៩៥ ពាក់ស្លាកលេខ ភ្នំពេញ2A-7624 ចំនួន០១ គ្រឿង (មានសោ), កាំភ្លើងខ្លីលេខ S1366 ចំនួន០១ ដើម (ខូច) និងគ្រាប់ចំនួន០១ គ្រាប់, ទូរស័ព្ទម៉ាកណូគាពណ៌ខ្មៅ (ចុចពិល) ចំនួន០២ គ្រឿង, អត្តសញ្ញាណប័ណ្ណឈ្មោះ [redacted] សំអាត ចំនួន០១, កាត Angkor Tep Group ចំនួន០១, កាំភ្លើងកែច្នៃចំនួន០១ ដើម, កាំបិតផែងចំនួន០២ ដើម, សៀវភៅចុះបញ្ជីលក់ថ្នាំញៀនចំនួន០១ ក្បាល, កាបូបខ្មៅពណ៌ខ្មៅចំនួន០១, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១ (គ្មានថ្ម), ថង់សំរាប់ច្រកថ្នាំញៀនចំនួន០១ កញ្ចប់ធំ, ស្ករក្រាមចំនួន០១ ប្រអប់, សាជូរចំនួន០១ កញ្ចប់ធំ, ប្រអប់ដាក់ថ្នាំ



Scanned with CamScanner

ញៀនចំនួន០១ ប្រអប់, កំប៉ុងដាក់ថ្នាំញៀនចំនួន០១, ឧបករណ៍ធ្វើតេស្តទឹកនោមចំនួន០២, វិក័យប័ត្រវឹងចំនួន១០ សន្លឹក និងសម្ភារៈប្រើប្រាស់ថ្នាំញៀនចំនួន០១ កញ្ចប់ធំ ត្រូវរឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

៣./សាលក្រមជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ,ឈ្មោ[redacted]ឿយអេង ហៅ ញ៉ាំញ់, ចិន ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted] ម៉េង ហៅ [redacted] ផាន់នី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចនេះមានសិទ្ធិប្តឹងទាស់, ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា និងត្រា[redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ខេត្តព្រះវិហារ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]